# ដំបូន្មានរបស់ព្រះអម្ចាស់ចំពោះពួកអ្នកផ្សព្វផ្សាយសាសនា នៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៣០–៣៦

សូមសិក្សាដំបូន្មានរបស់ព្រះអង្គសង្គ្រោះចំពោះបុគ្គលដែលបានរាយបញ្ជីនៅខាងក្រោម និងពិភាក្សាអំពីសំណួរដែលមានបន្ទាប់ ។

គោលលទ្ធិ និងសេចក្ដីសញ្ញា ៣១:១–៥ ( ថូម៉ាស បី ម៉ាស )

- តើមានសេចក្ដីពិតអ្វីខ្លះចេញពីខគម្ពីរទាំងនេះ ដែលអាចជួយអ្នកឲ្យយល់ពីមូលហេតុដែលព្រះអង្គសង្គ្រោះបង្គាប់ឲ្យយើងចែកចាយដំណឹងល្អរបស់ទ្រង់ ?
- ហេតុអ្វីបានជាអ្នកគិតថា ព្រះយេស៊ូវគ្រីស្ទសំដៅដំណឹងល្អរបស់ទ្រង់ថាជា « ដំណឹងដ៏រីករាយ នៃសេចក្ដីអំណរដ៏ធំ » ? ( ខទី ៣ ) ។ តើដំណឹងល្អរបស់ព្រះអង្គសង្គ្រោះនាំឲ្យអ្នកមានអំណរយ៉ាងដូចម្ដេច ?

គោលលទ្ធិ និងសេចក្ដីសញ្ញា ៣៣:១–៧, ១០–១២ ( អែសរ៉ា ធេយ័រ និង ណូរត្រុព ស្វ៊ីត )

- តើមានសេចក្ដីពិតអ្វីខ្លះចេញពីខគម្ពីរទាំងនេះ ដែលអាចជួយអ្នកឲ្យយល់ពីមូលហេតុដែលព្រះអង្គសង្គ្រោះបង្គាប់ឲ្យយើងចែកចាយដំណឹងល្អរបស់ទ្រង់ ?
- ហេតុអ្វីព្រះអម្ចាស់អាចសព្វព្រះទ័យឲ្យដំណឹងល្អរបស់ទ្រង់ បានប្រកាសដោយសំឡេងឮយ៉ាងខ្លាំងដូចជា « សំឡេងត្រែ » ? ( ខទី ២ ) ។

គោលលទ្ធិ និងសេចក្ដីសញ្ញា ៣៤:១–៧ ( អូរសុន ប្រាត្ត )

- តើមានសេចក្ដីពិតអ្វីខ្លះចេញពីខគម្ពីរទាំងនេះ ដែលអាចជួយអ្នកឲ្យយល់ពីមូលហេតុដែលព្រះអង្គសង្គ្រោះបង្គាប់ឲ្យយើងចែកចាយដំណឹងល្អរបស់ទ្រង់ ?
- ហេតុអ្វីបានជាអ្នកគិតថា យើង « មានពរលើសលែងទៅទៀត » ( ខទី ៥ ) ពីព្រោះត្រូវបានហៅឲ្យទៅផ្សាយដំណឹងល្អរបស់ព្រះអង្គសង្គ្រោះ ជាងការដែលយើងគ្រាន់តែជឿលើដំណឹងល្អនោះ ?

គោលលទ្ធិ និងសេចក្ដីសញ្ញា ៣៥:១–៣, ៦–៨, ១២–១៣ ( ស៊ីឌនី រិកដុន )

- តើមានសេចក្ដីពិតអ្វីខ្លះចេញពីខគម្ពីរទាំងនេះ ដែលអាចជួយអ្នកឲ្យយល់ពីមូលហេតុដែលព្រះអង្គសង្គ្រោះបង្គាប់ឲ្យយើងចែកចាយដំណឹងល្អរបស់ទ្រង់ ?
- ហេតុអ្វីអ្នកគិតថា ព្រះអម្ចាស់ហៅថា « ពួកអ្នកដែលពុំបានរៀនសូត្រ » និងមនុស្សដែលមិនមានបទពិសោធន៍ឲ្យប្រកាសដំណឹងល្អរបស់ទ្រង់ទៅកាន់ « សាសន៍ទាំងឡាយ » នៃផែនដីនេះ ? ( ខទី ១៣ ) ។



© 2023 by Intellectual Reserve, Inc. All rights reserved.

PD80007812_258_151-1